**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# លទ្ធផលប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ
# សម័យប្រឡង៖ ១៩ សីហា ២០១៩

ការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ដែលបានប្រព្រឹត្តទៅកាលពីថ្ងៃទី១៩-២០ ខែសីហា ឆ្នាំ២០១៩ មានមណ្ឌលប្រឡងនៅគ្រប់រាជធានី ខេត្ត សរុប ២០២មណ្ឌល បន្ទប់ប្រឡង ៤ ៧២៤បន្ទប់ និងបេក្ខជនចុះឈ្មោះក្នុងបញ្ជីសរុប ១១៧ ០៤៣នាក់ ដែលក្នុងនោះ ៩០ ៩៦៦នាក់ជាបេក្ខជនចំណេះទូទៅ ១៨ ៤៥៧នាក់ជាបេក្ខជនស្វ័យរិន ៤ ៥៦៤នាក់ជាបេក្ខជនបំពេញវិជ្ជា និង ៣ ០៥៦នាក់ជាបេក្ខជនស្វ័យរិនបំពេញវិជ្ជា ។ បេក្ខជនអវត្តមានមានចំនួន ១ ៨៣៥នាក់។ ដំណើរការនៃការប្រឡង ទាំងដំណើរការសំណេរ កំណែ និងស្រង់ពិន្ទុដោយកុំព្យូទ័របានប្រព្រឹត្តទៅប្រកបដោយជោគជ័យ ពុំមានឧបទ្ទវហេតុអ្វីគួរឱ្យកត់សម្គាល់ឡើយ។ ការប្រកាសលទ្ធផលប្រព្រឹត្តទៅនៅរសៀលថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៩ សម្រាប់រាជធានីភ្នំពេញ និងខេត្តកណ្តាល និង នៅព្រឹកថ្ងៃទី១០ ខែកញ្ញា ឆ្នាំ២០១៩ សម្រាប់ខេត្តដទៃទៀត។

បេក្ខជនប្រឡងជាប់មានចំនួន ៧៩ ០៥២ នាក់ ត្រូវជា ៦៨.៦២% (បើប្រៀបធៀបនឹងឆ្នាំ២០១៨ ចំនួន ៦៧.០៧%) ក្នុងនោះបេក្ខជនដែលទទួលបាននិទ្ទេស A មានចំនួន ៤៤៣ នាក់ (ឆ្នាំ២០១៨ ចំនួន ៤០៨ នាក់) និទ្ទេស B មាន ចំនួន ២ ៤៣០ នាក់ (ឆ្នាំ២០១៨ ចំនួន ២ ២២២ នាក់) និទ្ទេស C មានចំនួន ៥ ៨៤៧ នាក់ (ឆ្នាំ២០១៨ ចំនួន ៦ ០៤១ នាក់) និទ្ទេស D មានចំនួន ១៤ ១០០ នាក់ (ឆ្នាំ២០១៨ ចំនួន ១៥ ១៨០ នាក់) និងនិទ្ទេស E មានចំនួន ៥៦ ២៣២ នាក់ (ឆ្នាំ២០១៨ ចំនួន ៥២ ១៨៣ នាក់)។

ក្នុងចំណោមបេក្ខជនទទួលបាននិទ្ទេស A ចំនួន ៤៤៣ នាក់ មកពីរាជធានីភ្នំពេញ ១៤១ នាក់ ខេត្តសៀមរាប ៣៨ នាក់ បាត់ដំបង ៣២ នាក់ តាកែវ ២៩ នាក់ កំពង់ចាម ២៧ នាក់ ព្រៃវែង ២៧ នាក់ បន្ទាយមានជ័យ ២៥ នាក់ កណ្តាល ២៣ នាក់ កំពត ២៣ នាក់ ត្បូងឃ្មុំ ១៥ នាក់ កំពង់ធំ ១៤ នាក់ ព្រះសីហនុ ១៣ នាក់ ស្វាយរៀង ៨ នាក់ ពោធិ៍សាត់ ៧ នាក់ កំពង់ឆ្នាំង ៦ នាក់ កំពង់ស្ពឺ ៦ នាក់ ក្រចេះ ៤ នាក់ រតនគិរី ២ នាក់ កោះកុង ១ នាក់ មណ្ឌលគិរី ១ នាក់ និងឧត្តរមានជ័យ ១ នាក់។

ថ្ងៃចន្ទ ១១កើត ខែភទ្របទ ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០១៩

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh